E439/5

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de première instance

សំណុំរឿងលេខ: ០០២/១៩ កញ្ញា ២០០៧/អវតក/អជសដ
**Case File/Dossier No. 002/19-09-2007-ECCC/TC**

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 27 / 02 / 2017
ម៉ោង (Time/Heure): 15:30
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

ចំពោះមុខ: ចៅក្រម និល ណុន ជាប្រធាន
ចៅក្រម Jean-Marc LAVERGNE
ចៅក្រម យ៉ា សុខន
ចៅក្រម Claudia FENZ
ចៅក្រម យូរ ឧត្តារា

កាលបរិច្ឆេទ: ថ្ងៃទី ២៧ ខែ កុម្ភៈ ឆ្នាំ ២០១៧
ភាសាដើម: ខ្មែរ/អង់គ្លេស/បារាំង
ចំណាត់ថ្នាក់ឯកសារ: សាធារណៈ

---

# សេចក្តីសម្រេចលើការកាត់បន្ថយវិសាលភាពនៃសំណុំរឿង ០០២

---

**សហព្រះរាជអាជ្ញា**
ជា លាង
Nicholas KOUMJIAN

**ជនជាប់ចោទ**
នួន ជា
ខៀវ សំផន

**សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី**
ពេជ អង្គ
Marie GIRAUD

**មេធាវីជនជាប់ចោទ**
សុន អរុណ
Victor KOPPE
គង់ សំអុន
Anta GUISSÉ

## ១. សេចក្ដីផ្ដើម

១. អង្គជំនុំជម្រះសាលាដំបូងបានទទួលសំណើរបស់សហព្រះរាជអាជ្ញា អនុលោមតាមវិធាន ៨៩*ស្ទួន បី* នៃវិធានផ្ទៃក្នុង សុំឱ្យបិទបញ្ចប់កិច្ចដំណើរការនីតិវិធីចំពោះអង្គហេតុនៅក្នុងដីកាដំណោះស្រាយនៃសំណុំរឿង ០០២ បន្ទាប់ពីមានសេចក្ដីសម្រេចបំបែកកិច្ចដំណើរការនីតិវិធីសវនាការកន្លងមក ដែលអង្គហេតុកំពុងពិចារណាទាំងនេះ មិនត្រូវបានបញ្ចូលទៅក្នុងវិសាលភាពនៃសំណុំរឿង ០០២/០១ ឬ ០០២/០២ ("សំណើសុំបញ្ចប់កិច្ចដំណើរការនីតិវិធី")[1]។

២. នៅថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ២០១១ អនុលោមតាមវិធាន ៨៩ *ស្ទួនពីរ* នៃវិធានផ្ទៃក្នុង អង្គជំនុំជម្រះបានចេញដីកាបំបែកកិច្ចដំណើរការនីតិវិធីសវនាការនៅក្នុងសំណុំរឿង ០០២ ទៅជាសំណុំរឿងពីរ ឬ ច្រើន ("សេចក្ដីសម្រេចលើកទីមួយលើការបំបែកកិច្ចដំណើរការនីតិវិធី")[2]។ នៅថ្ងៃទី ០៨ ខែ តុលា ឆ្នាំ ២០១២ អង្គជំនុំជម្រះបានសម្រេចពង្រីកវិសាលភាពនៃសំណុំរឿង ០០២/០១[3]។ នៅថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ២០១៣ សេចក្ដីសម្រេចលើកទីមួយលើការបំបែកកិច្ចដំណើរការនីតិវិធី ត្រូវបានអង្គជំនុំជម្រះតុលាការកំពូលប្រកាសថាមិនមានសុពលភាព ដែលការប្រកាសនេះបានធ្វើឱ្យសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ក្នុងការពង្រីកវិសាលភាពនៃសំណុំរឿង ០០២/០១ ទៅជាមោឃៈផងដែរ[4]។ ជាលទ្ធផល នៅថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០១៣ អង្គជំនុំជម្រះសាលាដំបូងបានចេញសេចក្ដីសម្រេចលើកទីពីរលើការបំបែកកិច្ចដំណើរការនីតិវិធី[5] ដែលត្រូវបានអង្គជំនុំជម្រះ

---

[1] ចម្លើយតបរបស់សហព្រះរាជអាជ្ញា ទៅនឹងសំណើរបស់សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណីសុំសេចក្ដីបញ្ជាក់ទាក់ទងនឹងអង្គហេតុដែលនៅសេសសល់ក្នុងសំណុំរឿង០០២, ឯកសារ E439/3 ចុះថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ២០១៦, កថាខណ្ឌ ៦, ១៧។

[2] ដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធី អនុលោមតាមវិធាន ៨៩ ស្ទួនពីរ នៃវិធានផ្ទៃក្នុង, ឯកសារ E124 ចុះថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ២០១១។

[3] សេចក្ដីជូនដំណឹងស្ដីពីសេចក្ដីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញា ដែលស្នើសុំដាក់បញ្ចូលទីតាំងឧក្រិដ្ឋកម្មបន្ថែមទៅក្នុងវិសាលភាពនៃការជំនុំជម្រះក្នុងសំណុំរឿង ០០២/០១, ឯកសារ E163។ ពេលវេលាកំណត់នៃការដាក់សេចក្ដីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោលពាក់ព័ន្ធនឹងច្បាប់ជាធរមាន, ឯកសារ E163/5 ចុះថ្ងៃទី ០៨ ខែ តុលា ឆ្នាំ ២០១២។

[4] សេចក្ដីសម្រេចលើបណ្ដឹងសាទុក្ខភ្លាមៗរបស់សហព្រះរាជអាជ្ញាប្រឆាំងនឹងសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ស្ដីពីវិសាលភាពនៃសំណុំរឿង ០០២/០១ (អជតក), ឯកសារ E163/5/1/13 ចុះថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ២០១៣, កថាខណ្ឌ ៥២។

[5] សេចក្ដីសម្រេចលើការបំបែកកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង ០០២ បន្ទាប់ពីមានសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូល ចុះថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ២០១៣, ឯកសារ E284 ចុះថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០១៣។

01396386



តុលាការកំពូលគាំទ្រ នៅថ្ងៃទី ២៣ ខែ កក្កដា ឆ្នាំ ២០១៣[6]។ នៅថ្ងៃទី ០៤ ខែ មេសា ឆ្នាំ ២០១៤ អង្គជំនុំជម្រះសាលាដំបូង បានចេញសេចក្តីសម្រេចបំបែកកិច្ចដំណើរការនីតិវិធីបន្ថែមលើសំណុំរឿង ០០២ និងវិសាលភាពនៃសំណុំរឿង ០០២/០២ ("សេចក្តីសម្រេចលើការបំបែកកិច្ចដំណើរការនីតិវិធីបន្ថែម")[7]។ អង្គជំនុំជម្រះសាលាដំបូងបានសម្រេចមិនដាក់បញ្ចូលនូវអង្គហេតុ បទចោទ និងទីតាំងឧក្រិដ្ឋកម្មមួយចំនួនទៅក្នុងវិសាលភាពនៃសំណុំរឿង ០០២/០២[8]។ អង្គជំនុំជម្រះសាលាដំបូងសម្រេចថា ដោយសារតែអង្គជំនុំជម្រះមិនបានទទួលសំណើពីសហព្រះរាជអាជ្ញាសុំឱ្យដកចេញពីដីកាដំណោះស្រាយ នូវអង្គហេតុដែលមិនបានបញ្ចូលទៅក្នុងវិសាលភាពនៃសំណុំរឿង ០០២/០២ នោះ អង្គជំនុំជម្រះ"ពុំចាំបាច់ដោះស្រាយបញ្ហានេះនៅក្នុងដំណាក់កាលនៃកិច្ចដំណើរការនីតិវិធីនេះទេ"[9]។ បន្ទាប់ពីសេចក្តីសម្រេចនេះត្រូវបានមេធាវីការពារក្តី ខៀវ សំផន ប្តឹងសាទុក្ខ អង្គជំនុំជម្រះតុលាការកំពូលសម្រេចតម្កល់ការបំបែកកិច្ចដំណើរការនីតិវិធីបន្ថែមលើសំណុំរឿង០០២ និងប្រកាសផ្អាកបណ្តោះអាសន្នចំពោះអង្គហេតុដែលស្ថិតក្រៅវិសាលភាពនៃសំណុំរឿង ០០២/០១ និងសំណុំរឿង ០០២/០២ ដោយរង់ចាំការសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង[10]។ បទចោទ

---

[6] សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗប្រឆាំងនឹងសេចក្តីសម្រេចលើកទីពីររបស់អង្គជំនុំជម្រះសាលាដំបូង ស្តីពីការបំបែកកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង ០០២ ៖ សេចក្តីសង្ខេបនៃសំអាងហេតុ, ឯកសារ E284/4/7 ចុះថ្ងៃទី ២៣ ខែ កក្កដា ខែ ឆ្នាំ ២០១៣, កថាខណ្ឌ ១៣ ។ សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗប្រឆាំងនឹងសេចក្តីសម្រេចលើកទីពីររបស់អង្គជំនុំជម្រះសាលាដំបូងស្តីពីការបំបែកកិច្ចដំណើរការនីតិវិធីនៃសំណុំរឿង ០០២, ឯកសារ E284/4/8 ចុះថ្ងៃទី ២៥ ខែ វិច្ឆិកា ឆ្នាំ ២០១៣ ("សេចក្តីសម្រេចរបស់ អ.ជ.ត.ក លើសេចក្តីសម្រេចលើកទីពីររបស់ អ.ជ.ស.ដ ស្តីពីការបំបែកកិច្ចដំណើរការនីតិវិធី"), កថាខណ្ឌ ៧៦។

[7] សេចក្តីសម្រេចលើការបំបែកកិច្ចដំណើរការនីតិវិធីបន្ថែមនៃសំណុំរឿង ០០២ និងវិសាលភាពនៃសំណុំរឿង ០០២/០២, ឯកសារ E301/9/1 ចុះថ្ងៃទី ០៤ ខែ មេសា ឆ្នាំ ២០១៤ ("សេចក្តីសម្រេចលើការបំបែកកិច្ចដំណើរការនីតិវិធីបន្ថែម")។

[8] សេចក្តីសម្រេចលើការបំបែកកិច្ចដំណើរការនីតិវិធីបន្ថែម, កថាខណ្ឌ ៤៥។ ជាឧបសម្ព័ន្ធនៃសេចក្តីសម្រេចលើការបំបែកកិច្ចដំណើរការនីតិវិធីបន្ថែមដែលជាបញ្ជីនៃកថាខណ្ឌ និងផ្នែកដីកាដំណោះស្រាយពាក់ព័ន្ធសំណុំរឿង ០០២៖ ឯកសារ E301/9/1.1។

[9] សេចក្តីសម្រេចលើការបំបែកកិច្ចដំណើរការនីតិវិធីបន្ថែម, កថាខណ្ឌ ៤៥។

[10] សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗរបស់ ខៀវ សំផន ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងលើការបំបែកកិច្ចដំណើរការនីតិវិធីបន្ថែមនៃសំណុំរឿង ០០២ និងវិសាលភាពនៃសំណុំរឿង ០០២/០២, ឯកសារ E301/9/1/1/3 ចុះថ្ងៃទី ២៩ ខែ កក្កដា ឆ្នាំ ២០១៤, កថាខណ្ឌ ៨៨ ដល់ ៩១ ("សេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូល")។

ប្រកាន់ប្រឆាំង ខៀវ សំផន និង នួន ជា ពាក់ព័ន្ធទៅនឹងអង្គហេតុនៅក្នុងវិសាលភាពនៃសំណុំរឿង ០០២/០១ ត្រូវបានជំនុំជម្រះរួចរាល់ជាស្ថាពរ[11]។

៣. នៅថ្ងៃទី ០៩ ខែ កញ្ញា ឆ្នាំ ២០១៦ សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី បានដាក់សំណើសុំការបញ្ជាក់បំភ្លឺចំពោះអង្គហេតុដែលនៅសេសសល់ក្នុងសំណុំរឿង ០០២ ("សំណើសុំការបញ្ជាក់បំភ្លឺ")[12]។ ភាគីដទៃទៀតនៃសំណុំរឿង ០០២/០២ បានដាក់ចម្លើយតបជាបន្តបន្ទាប់ ដែលរួមមានសំណើសុំបញ្ចប់កិច្ចដំណើរការនីតិវិធីផងដែរ[13]។ នៅថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ២០១៦ អង្គជំនុំជម្រះសាលាដំបូងបានកត់សម្គាល់ថា ចម្លើយតបរបស់ នួន ជា បានលើកឡើងនូវបញ្ហាថ្មីមួយទាក់ទងនឹងការដកមន្ទីរសន្តិសុខក្រូចឆ្មារ ចេញពីវិសាលភាពនៃសំណុំរឿង ០០២/០២ ដូច្នេះហើយទើបអង្គជំនុំជម្រះអនុញ្ញាតឱ្យភាគីដាក់ចម្លើយតបចំពោះបញ្ហានេះ[14]។ មានតែសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីប៉ុណ្ណោះ ដែលបានដាក់សារណានៅថ្ងៃទី ២៣ ខែកញ្ញា ឆ្នាំ ២០១៦[15]។ នៅថ្ងៃទី ១១ ខែ មករា ឆ្នាំ ២០១៧ អង្គជំនុំជម្រះសាលាដំបូងបានស្តាប់សារណាផ្ទាល់មាត់របស់ភាគីពីស្ថានភាពនៃអង្គហេតុនានានៅក្នុងដីកាដំណោះស្រាយដែលស្ថិតក្រៅវិសាលភាពនៃសំណុំរឿង ០០២/០១ និងសំណុំរឿង ០០២/០២ ("អង្គហេតុដែលកំពុងពិចារណា")។

---

[11] សាលដីកាលើសំណុំរឿង ០០២/០១, ឯកសារ F36 ចុះថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ២០១៦។

[12] សំណើរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីសុំការបញ្ជាក់បំភ្លឺទាក់ទងនឹងអង្គហេតុដែលនៅសេសសល់ក្នុងសំណុំរឿង០០២, ឯកសារ E439 ចុះថ្ងៃទី ០៩ ខែ កញ្ញា ឆ្នាំ ២០១៦, កថាខណ្ឌ ១, ១០។

[13] *សូមមើល* Observations de la Défense de M. KHIEU Samphân en réponse à la demande de clarification des Parties civiles concernant les poursuites restantes du dossier 002, ឯកសារ E439/1 ("ចម្លើយតបរបស់ ខៀវ សំផន")។ ចម្លើយតបរបស់ នួន ជា ចំពោះសំណើរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីសុំសេចក្តីបញ្ជាក់ទាក់ទងនឹងអង្គហេតុដែលនៅសេសសល់ក្នុងសំណុំរឿង ០០២, ឯកសារ E439/2 ចុះថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ២០១៦ ("ចម្លើយតបរបស់ នួន ជា")។ សំណើសុំបញ្ចប់កិច្ចដំណើរការនីតិវិធី។

[14] សូមមើល សារអេឡិចត្រូនិករបស់មន្ត្រីច្បាប់អង្គជំនុំជម្រះសាលាដំបូង, ចុះថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ២០១៦។

[15] ចម្លើយតបរបស់សហមេធាវីនាំមុខទៅនឹងចម្លើយតបរបស់ នួន ជា ទៅនឹងសំណើសុំសេចក្តីបញ្ជាក់ទាក់ទងនឹងអង្គហេតុដែលនៅសេសសល់ក្នុងសំណុំរឿង០០២, ឯកសារ E439/4 ចុះថ្ងៃទី ២៣ ខែ កញ្ញា ឆ្នាំ ២០១៦ ("ចម្លើយតបរបស់សហមេធាវីនាំមុខ")។

## ២. សារណា

៤. សហព្រះរាជអាជ្ញាបានលើកឡើងថា ដោយអនុលោមតាមវិធាន ៨៩ ស្ទួនបី នៃវិធានផ្ទៃក្នុង វាជាប្រយោជន៍យុត្តិធម៌សម្រាប់អង្គជំនុំជម្រះសាលាដំបូង ដែលត្រូវបញ្ចប់កិច្ចដំណើរការនីតិវិធីចំពោះអង្គហេតុទាំងអស់ ដែលអង្គជំនុំជម្រះបានដកចេញពីវិសាលភាពនៃសំណុំរឿង ០០២/០២[16]។ សហព្រះរាជអាជ្ញាកត់សម្គាល់ពីការគោរពសិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់នៅក្នុងសំណុំរឿង ០០២/០២ ក្នុងការទទួលបានព័ត៌មានឆាប់រហ័ស និងមានតម្លាភាពទាក់ទងនឹងវឌ្ឍនភាពនៃសំណុំរឿងនាពេលអនាគត[17]។ សហព្រះរាជអាជ្ញាបានអះអាងថា ភាគីទាំងអស់ និង អ.វ.ត.ក នឹងទទួលបានប្រយោជន៍ពីភាពច្បាស់លាស់ចំពោះបញ្ហានេះ ហើយការបញ្ជាក់បំភ្លឺនឹងជួយដល់ការបញ្ចប់សវនាការដោយត្រឹមត្រូវ[18]។ សហព្រះរាជអាជ្ញាបានលើកឡើងថា នៅក្នុងខែ ធ្នូ ឆ្នាំ ២០១៣ ពួកគាត់បានស្នើសុំឱ្យបញ្ចូល ឬ ដកចេញនូវអង្គហេតុមួយចំនួនពីវិសាលភាពនៃសំណុំរឿង០០២/០២ ហើយបានបញ្ជាក់ជាសាធារណៈថា ពួកគាត់ប្រមើលថា នឹងមិនមានការជំនុំជម្រះទីបី ទាក់ទងទៅនឹងអង្គហេតុដែលបានដកចេញពីវិសាលភាពនៃសំណុំរឿង ០០២/០២ ឡើយ។ បន្ថែមលើនេះទៀត សហព្រះរាជអាជ្ញាបានលើកឡើងថា "រាល់ការចោទប្រកាន់តាមផ្លូវច្បាប់ទាំងអស់នៅក្នុងដីកាដំណោះស្រាយ" ត្រូវបានពិនិត្យយ៉ាងពេញលេញនៅក្នុងសំណុំរឿង ០០២/០១ និង សំណុំរឿង ០០២/០២។ សហព្រះរាជអាជ្ញាបានលើកឡើងថា នៅចុងបញ្ចប់នៃសំណុំរឿង ០០២/០២ អង្គជំនុំជម្រះសាលាដំបូងនឹងត្រូវស្តាប់ ឬ ទទួលយកភស្តុតាងស្តីពីឧក្រិដ្ឋកម្មជាច្រើន ដែលភាពជាតំណាងយ៉ាងសមស្របសម្រាប់គោលនយោបាយឧក្រិដ្ឋកម្មនៃរបបកម្ពុជាប្រជាធិបតេយ្យ និងជាកម្រិតពិតប្រាកដនៃការទទួលខុសត្រូវព្រហ្មទណ្ឌរបស់ជនជាប់ចោទ[19]។

៥. សហព្រះរាជអាជ្ញាបានកត់សម្គាល់ថា បន្ទាប់ពីមានសេចក្តីសម្រេចលើការបំបែកកិច្ចដំណើរការនីតិវិធីបន្ថែម ដែលក្នុងសេចក្តីសម្រេចនោះអង្គជំនុំជម្រះសាលាដំបូងមិនបានដោះស្រាយច្បាស់លាស់អំពីការដកចេញនូវអង្គហេតុដែលនៅសេសសល់ ទើបកិច្ចប្រជុំពេញអង្គរបស់ អ.វ.ត.ក កាលពីខែ មករា ឆ្នាំ ២០១៥ បានអនុម័តលើវិធាន ៨៩ *ស្ទួនបី* នៃវិធានផ្ទៃក្នុង។ វិធាននេះអនុញ្ញាត

---

[16] សំណើសុំបញ្ចប់កិច្ចដំណើរការនីតិវិធី, កថាខណ្ឌ ៦, ១៧។

[17] សំណើសុំបញ្ចប់កិច្ចដំណើរការនីតិវិធី, កថាខណ្ឌ ២។

[18] សំណើសុំបញ្ចប់កិច្ចដំណើរការនីតិវិធី, កថាខណ្ឌ ២, ៦។

[19] សំណើសុំបញ្ចប់កិច្ចដំណើរការនីតិវិធី, កថាខណ្ឌ ៥, ១៣ ដល់១៥។ ប្រតិចារឹកសវនាការ ចុះថ្ងៃទី ១១ ខែ មករា ឆ្នាំ ២០១៧, ទំព័រ ៩ ដល់១២ (សេចក្តីព្រាង)។

ឲ្យអង្គជំនុំជម្រះសាលាដំបូងអាចកាត់បន្ថយវិសាលភាពនៃការជំនុំជម្រះ ដោយដកចេញនូវអង្គហេតុដែលបានកំណត់នៅក្នុងដីកាដំណោះស្រាយ និងតម្រូវឲ្យបញ្ចប់កិច្ចដំណើរការនីតិវិធីទាក់ទងអង្គហេតុដែលបានដកចេញទាំងអស់នោះ[20]។ សហព្រះរាជអាជ្ញាបានលើកឡើងថា ការកាត់បន្ថយវិសាលភាពនៃការជំនុំជម្រះ អនុលោមតាមវិធាន ៨៩ ស្ទួនបី នៃវិធានផ្ទៃក្នុង នឹងមិនប៉ះពាល់ដល់ការចូលរួមរបស់ដើមបណ្ដឹងរដ្ឋប្បវេណី ឬ សមាសភាពនៃបណ្ដុំដើមបណ្ដឹងរដ្ឋប្បវេណីឡើយ ហើយជនរងគ្រោះទាំងអស់ ដែលត្រូវបានអនុញ្ញាតឲ្យចូលរួមក្នុងសំណុំរឿង ០០២ នឹងនៅតែបន្តមានសិទ្ធិចូលរួមដដែល បន្ទាប់ពីបញ្ចប់កិច្ចដំណើរការនីតិវិធី[21]។

៦. សហមេធាវីនាំមុខបានលើកឡើងថា ដើមបណ្ដឹងរដ្ឋប្បវេណីដែល "រងផលប៉ះពាល់ដោយផ្ទាល់ពីស្ថានភាពនៃអង្គហេតុដែលនៅសេសសល់" មានសិទ្ធិទទួលបានសច្ចភាពផ្លូវច្បាប់ និងទទួលបានការជូនដំណឹងទាក់ទងនឹងការចោទប្រកាន់ទាំងអស់នៅក្នុងសំណុំរឿង០០២[22]។ សហមេធាវីនាំមុខបានកត់សម្គាល់ថា ដើមបណ្ដឹងរដ្ឋប្បវេណីចំនួន ៤៦៦ នាក់ ត្រូវបានការិយាល័យសហចៅក្រមស៊ើបអង្កេតទទួលស្គាល់ថាជាជនរងគ្រោះដោយផ្ទាល់ ឬ ដោយប្រយោលនៃអំពើដែលទទួលរងផលប៉ះពាល់នៃអង្គហេតុដែលស្ថិតនៅក្រៅវិសាលភាពនៃសំណុំរឿង ០០២/០១ និង ០០២/០២ ("ដើមបណ្ដឹងរដ្ឋប្បវេណីដែលទទួលរងផលប៉ះពាល់")[23]។ សហមេធាវីនាំមុខបានលើកឡើងថា កត្តាខាងក្រោមគឺពាក់ព័ន្ធជាមួយសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះលើស្ថានភាពនៃកិច្ចដំណើរការនីតិវិធី ៖ (១) មរណភាពរបស់ដើមបណ្ដឹងរដ្ឋប្បវេណីជាងពីររយនាក់ចាប់តាំងពីពេលចាប់ផ្ដើមសំណុំរឿង ០០២ (២) វ័យចាស់ជរា ឬ ស្ថានភាពសុខភាពមិនល្អរបស់ដើមបណ្ដឹងរដ្ឋប្បវេណីជាច្រើនដែលលែងមានលទ្ធភាពចូលរួមដោយផ្ទាល់នៅក្នុងកិច្ចដំណើរការនីតិវិធី ឬចូលរួមក្នុងវេទិកាទាក់ទងនឹងសំណង និង (៣) រយៈពេលនៃដំណើរការនីតិវិធីសំណុំរឿង ០០២ ដែលបានចាប់ផ្ដើមតាំងពីជិត ១០ ឆ្នាំមុន។ សហមេធាវីនាំមុខក៏បានលើកឡើងផងដែរថា ដើមបណ្ដឹងរដ្ឋប្បវេណីនៅ

[20] សំណើសុំបញ្ចប់កិច្ចដំណើរការនីតិវិធី, កថាខណ្ឌ ១១ ដល់១២។

[21] សំណើសុំបញ្ចប់កិច្ចដំណើរការនីតិវិធី, កថាខណ្ឌ ១៦។

[22] សំណើសុំការបញ្ជាក់បំភ្លឺ, កថាខណ្ឌ ៧ ដល់៨។

[23] សំណើសុំការបញ្ជាក់បំភ្លឺ, កថាខណ្ឌ ៧ ដល់៨។ ក្នុងអំឡុងពេលធ្វើសារណាផ្ទាល់មាត់ សហមេធាវីនាំមុខបានកត់សម្គាល់បន្ថែមថា មានតែដើមបណ្ដឹងរដ្ឋប្បវេណីដែលរងផលប៉ះពាល់៣៤នាក់ប៉ុណ្ណោះ ដែលត្រូវបានទទួលស្គាល់ដោយផ្អែកលើមូលដ្ឋាននៃអង្គហេតុដែលមិនត្រូវជំនុំជម្រះនៅក្នុងសំណុំរឿង ០០២។ ទោះជាយ៉ាងនេះក្ដី សហមេធាវីនាំមុខបានកត់សម្គាល់ថា ចំនួននេះមិនរួមបញ្ចូលដើមបណ្ដឹងរដ្ឋប្បវេណីដែលត្រូវបានទទួលស្គាល់ទាក់ទងនឹងការប្រព្រឹត្តិទៅលើពុទ្ធសាសនិកជន និងការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទីបីឡើយ(ប្រតិចារឹកសវនាការចុះថ្ងៃទី ១១ ខែ មករា ឆ្នាំ ២០១៧ ទំព័រ ៥ ដល់៦ (សេចក្ដីព្រាង))។

ក្នុងសំណុំរឿងនេះលែងចូលរួមជាលក្ខណៈបុគ្គលហើយ ដោយពួកគាត់បានចូលរួមជាក្រុម ហើយថាជនជាប់ចោទក្នុងសំណុំរឿង ០០២ ត្រូវបានផ្តន្ទាទោសរួចហើយ ចំពោះការចូលរួមរបស់ពួកគេនៅក្នុង "គម្រោងឧក្រិដ្ឋកម្ម ដែលជាចំណុចស្នូលនៃព្យសនកម្ម" ដែលដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់បានទទួលរង[24]។

៧. ដោយបានប្រឹក្សាជាមួយដើមបណ្តឹងរដ្ឋប្បវេណី រួមទាំងដើមបណ្តឹងរដ្ឋប្បវេណីដែលទទួលរងផលប៉ះពាល់ផងដែរនោះ សហមេធាវីនាំមុខបានលើកឡើងថា ជាគោលការណ៍ ដើមបណ្តឹងរដ្ឋប្បវេណីជាច្រើនរូបដែលស្ថិតក្នុងក្រុមរួមចង់ឲ្យធ្វើការជំនុំជម្រះទៅលើអង្គហេតុ និងបទចោទទាំងអស់ដែលមាននៅក្នុងដីកាដំណោះស្រាយនៃសំណុំរឿង ០០២។ ចំពោះបញ្ហានេះ សហមេធាវីនាំមុខបានលើកឡើងថា ព្យសនកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណីមួយចំនួន ពាក់ព័ន្ធទៅនឹងអង្គហេតុដែលមិនទាន់ត្រូវបានជំនុំជម្រះនៅឡើយនៅក្នុងសំណុំរឿង ០០២/០១ ឬ មិនត្រូវបានពិនិត្យនៅក្នុងសំណុំរឿង ០០២/០២។ ប៉ុន្តែចំពោះដើមបណ្តឹងរដ្ឋប្បវេណីជាច្រើនរូបផ្សេងទៀត អាទិភាពរបស់ពួកគាត់គឺស្វែងរកវិធានការមិនមែនតាមផ្លូវតុលាការ ដើម្បីគាំទ្រជីវភាពប្រចាំថ្ងៃ និងដើម្បីឲ្យពួកគាត់អាចនិយាយចេញអំពីអ្វីដែលពួកគាត់បានជួបប្រទះ[25]។

៨. មេធាវីការពារក្តី នួន ជា បានលើកឡើងថា អង្គហេតុដែលត្រូវបានពិនិត្យ ពិភាក្សាដេញដោលរួចហើយនៅក្នុងសំណុំរឿង ០០២/០២ ធំទូលាយជាងកម្រិតអប្បរមាដែលផ្តល់ដោយអង្គជំនុំជម្រះតុលាការកំពូល ហើយមេធាវីការពារក្តី នួន ជា បានសន្និដ្ឋានថា មិនមានភាពចាំបាច់ផ្លូវច្បាប់ដើម្បីមានការជំនុំជម្រះលើកទីបីសម្រាប់សំណុំរឿងនេះឡើយ។[26]

៩. មេធាវីការពារក្តី ខៀវ សំផន បានជំទាស់ចំពោះការអនុវត្តវិធាន ៨៩ *ស្ទួទ៍* នៃវិធានផ្ទៃក្នុង ដោយផ្អែកលើមូលដ្ឋានថា វាបានរំលោភទៅលើសិទ្ធិទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌តាមរបៀបពីរយ៉ាង ("ការជំទាស់របស់ ខៀវ សំផន")។ ទីមួយ ការអនុវត្តបែបនេះបានបំពានទៅលើគោលការណ៍នីត្យានុកូលភាព ដោយសារតែច្បាប់កម្ពុជាមិនអនុញ្ញាតឲ្យមានការជ្រៀតជ្រែក ឬ ព្រងើយកន្តើយចំពោះអ្វីដែលត្រូវបានសម្រេចនៅក្នុងដីកាដំណោះស្រាយ ដែលជាសេចក្តីសម្រេចតាមផ្លូវតុលាការនោះឡើយ។ ទីពីរ ការអនុវត្តបែបនេះអនុញ្ញាតឲ្យអង្គជំនុំជម្រះពឹងផ្អែកទៅលើភស្តុតាង

[24] ប្រតិចារិកសវនាការ ចុះថ្ងៃទី ១១ ខែ មករា ឆ្នាំ ២០១៧, ទំព័រ ៣ ដល់៩ (សេចក្តីព្រាង)។

[25] ប្រតិចារិកសវនាការ ចុះថ្ងៃទី ១១ ខែ មករា ឆ្នាំ ២០១៧, ទំព័រ ៣ ដល់៩ (សេចក្តីព្រាង)។

[26] ប្រតិចារិកសវនាការ ចុះថ្ងៃទី ១១ ខែ មករា ឆ្នាំ ២០១៧, ទំព័រ ១២ ដល់១៣ (សេចក្តីព្រាង)។

ដែលទាក់ទងជាមួយនឹងអង្គហេតុដែលត្រូវបានដកចេញ "ក្នុងកម្រិតមួយដែលវាអាចពាក់ព័ន្ធជាមួយនឹងអង្គហេតុដែលនៅសេសសល់ក្នុងវិសាលភាពនៃសំណុំរឿង"។ មេធាវីការពារក្តី ខៀវ សំផន បានពិចារណាថា នៅពេលកាត់បន្ថយវិសាលភាពនៃការជំនុំជម្រះដោយដកចេញនូវអង្គហេតុដែលបានកំណត់នៅក្នុងដីកាដំណោះស្រាយនោះ ការនេះនឹងរារាំងមិនឱ្យប្រើប្រាស់ភ័ស្តុតាងទាក់ទងជាមួយអង្គហេតុដែលត្រូវបានដកចេញ។ ប៉ុន្តែមេធាវីការពារក្តី ខៀវ សំផន បានលើកឡើងថា លទ្ធភាពដើម្បីបន្តកិច្ចដំណើរការនីតិវិធីចំពោះ "អង្គហេតុដែលនៅសេសសល់សម្រាប់ការជំនុំជម្រះក្រៅពីសំណុំរឿង ០០២/០២" គឺមិនអាចធ្វើបានក្នុងពេលវេលាសមស្របឡើយ ហើយថាអង្គជំនុំជម្រះសាលាដំបូងមិនមានជម្រើសផ្សេងក្រៅពីការបញ្ចប់កិច្ចដំណើរការនីតិវិធី ដោយសារមូលហេតុនៃសច្ចភាពផ្លូវច្បាប់ទេ។ ក្នុងន័យនេះមេធាវីការពារក្តី ខៀវ សំផន បានកត់សម្គាល់បន្ថែមថា យោងតាមអង្គជំនុំជម្រះតុលាការកំពូល សវនាការបន្តទៀតនៅក្នុងសំណុំរឿង ០០២ នឹងមិនមានមូលដ្ឋានភ័ស្តុតាងដូចគ្នាទៅនឹងសំណុំរឿង ០០២/០១ និង០០២/០២ ទេ ហេតុដូច្នេះតម្រូវឱ្យអង្គជំនុំជម្រះសាលាដំបូង "ចាប់ផ្តើមពីដំបូង"។ ការនេះនឹងធ្វើឱ្យការជំនុំជម្រះមិនអាចបញ្ចប់ក្នុងពេលវេលាសមស្រប[27]។ ជាចុងក្រោយ មេធាវីការពារក្តី ខៀវ សំផន បានអះអាងថា បញ្ហានេះគួរត្រូវបានបញ្ជាក់នៅក្នុងខែ មេសា ឆ្នាំ ២០១៤ ហើយថា អង្គជំនុំជម្រះសាលាដំបូងបានរំលោភបំពានទៅលើគោលការណ៍សច្ចភាពផ្លូវច្បាប់ និងគោលការណ៍ជាសារវ័ន្តដែលមានចែងនៅក្នុងវិធាន ២១ នៃវិធានផ្ទៃក្នុង[28]។

## ៣. **ច្បាប់ជាធរមាន**

១០. អនុលោមតាមវិធាន ៨៩ *ស្ទួនពីរ* នៃវិធានផ្ទៃក្នុង[29] នៅពេលប្រយោជន៍យុត្តិធម៌តម្រូវ នៅដំណាក់កាលណាមួយ អង្គជំនុំជម្រះអាចបង្គាប់ឱ្យបំបែកកិច្ចដំណើរការនីតិវិធីពាក់ព័ន្ធនឹងបទចោទខ្លះដែលមាននៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ។

១១. វិធាន ៨៩ *ស្ទួនបី*[30] នៃវិធានផ្ទៃក្នុងចែងថា "ដើម្បីធានាបាននូវកិច្ចដំណើរការនីតិវិធីមួយប្រកបដោយយុត្តិធម៌ អត្ថន័យ និងឆាប់រហ័ស ជាពិសេស ដោយពិចារណាលើលក្ខខណ្ឌតម្រូវជាក់លាក់

---

[27] ប្រតិចារឹកសវនាការ ចុះថ្ងៃទី ១១ ខែ មករា ឆ្នាំ ២០១៧, ទំព័រ ១៣ ដល់១៧ (សេចក្តីព្រាង) យោងទៅរកសេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូល, កថាខណ្ឌ ៧៦។

[28] ចម្លើយតបរបស់ ខៀវ សំផន, កថាខណ្ឌ ១២ ដល់១៤។

[29] វិធាន ៨៩ ស្ទួនពីរ នៃវិធានផ្ទៃក្នុង ត្រូវបានអនុម័តកាលពីថ្ងៃទី ២៣ ខែ កុម្ភៈ ឆ្នាំ ២០១១។

នៃកិច្ចដំណើរការនីតិវិធីនៅចំពោះមុខ អ.វ.ត.ក អង្គជំនុំជម្រះសាលាដំបូង អាចសម្រេចកាត់បន្ថយវិសាលភាពនៃការជំនុំជម្រះ ដោយដកចេញនូវអង្គហេតុមួយចំនួន ដែលមាននៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ។ អង្គជំនុំជម្រះសាលាដំបូងត្រូវធានាថា អង្គហេតុដែលនៅសល់ ត្រូវយកជាតំណាងចំពោះវិសាលភាពនៃដីកាសន្និដ្ឋានបញ្ជូនរឿងទៅជំនុំជម្រះ"[31]។ មុនពេលដកអង្គហេតុចេញពីវិសាលភាពនៃការជំនុំជម្រះ អង្គជំនុំជម្រះត្រូវស្ដាប់ការលើកឡើងរបស់ភាគីនីមួយៗ[32]។ អង្គជំនុំជម្រះសាលាដំបូងត្រូវបញ្ចប់កិច្ចដំណើរការនីតិវិធីពាក់ព័ន្ធនឹងអង្គហេតុដែលត្រូវបានដកចេញ។ នៅពេលដែលសេចក្ដីសម្រេចកាត់បន្ថយវិសាលភាពនៃការជំនុំជម្រះចូលជាស្ថាពរ អង្គហេតុដែលត្រូវបានដកចេញនឹងមិនអាចត្រូវបានប្រើជាមូលដ្ឋានសម្រាប់ដំណើរការនីតិវិធីប្រឆាំងនឹងជនជាប់ចោទដដែលនោះបានឡើយ[33]។ សេចក្ដីសម្រេចកាត់បន្ថយវិសាលភាពនៃដីកាបញ្ជូនរឿងទៅជំនុំជម្រះមិនប៉ះពាល់ដល់ការចូលរួមរបស់ដើមបណ្ដឹងរដ្ឋប្បវេណី ឬ សមាសភាពនៃបណ្ដុំដើមបណ្ដឹងរដ្ឋប្បវេណីឡើយ[34]។

## ៤. ការវិភាគ

១២. ជាដំបូង ដើម្បីជាការបញ្ជាក់បំភ្លឺ អង្គជំនុំជម្រះសាលាដំបូងកត់សម្គាល់ថា ពាក្យ "អង្គហេតុដែលកំពុងពិចារណា" គឺគ្របដណ្ដប់លើអង្គហេតុទាំងអស់ដែលបានកំណត់ក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ

---

[30] វិធាន ៨៩ ស្ទួនបី នៃវិធានផ្ទៃក្នុង ត្រូវបានអនុម័តកាលពីថ្ងៃទី ១៦ ខែ មករា ឆ្នាំ ២០១៥។

[31] វិធាន ៨៩ ស្ទួនបី(១) នៃវិធានផ្ទៃក្នុង។ អង្គជំនុំជម្រះសាលាដំបូងកត់សម្គាល់ថា វិធាន ៨៩ ស្ទួនពីរ នៃវិធានផ្ទៃក្នុងយោងទៅរកការបំបែកកិច្ចដំណើរការនីតិវិធីទាក់ទងទៅនឹង "បទចោទ" ចំណែកវិធាន ៨៩ ស្ទួនបី នៃវិធានផ្ទៃក្នុង យោងទៅរកការដកចេញនូវ"អង្គហេតុ"។ ទោះជាយ៉ាងនេះក្ដីអង្គជំនុំជម្រះសាលាដំបូងយល់ស្របជាមួយការសង្កេតរបស់អង្គជំនុំជម្រះតុលាការកំពូលដែលថា នៅក្នុងបរិបទ អ.វ.ត.ក "ការកម្រិតកំណត់លើបណ្ដឹងព្រហ្មទណ្ឌ ដែលតុលាការបានទទួល ត្រូវសម្រេចផ្អែកលើការចោទប្រកាន់ដែលមាននៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ មិនមែនដោយការកំណត់ប្រភេទនៃបទល្មើសនោះឡើយ"៖ សេចក្ដីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូល, កថាខណ្ឌ ១៨។ ពាក្យពេចន៍នៃវិធាន ៨៩ ស្ទួនបី នៃវិធានផ្ទៃក្នុង គឺច្បាស់លាស់ និងឆ្លុះបញ្ចាំងពីគោលជំហរនេះ ដែលថាអ្វីដែលសំខាន់គឺ "អង្គហេតុ"។

[32] វិធាន ៨៩ ស្ទួនបី(២) នៃវិធានផ្ទៃក្នុង។

[33] វិធាន ៨៩ ស្ទួនបី(៣) នៃវិធានផ្ទៃក្នុង។

[34] វិធាន ៨៩ ស្ទួនបី(៤) នៃវិធានផ្ទៃក្នុង។

ក្នុងសំណុំរឿង ០០២ ដែលមិនមាននៅក្នុងសំណុំរឿង ០០២/០១ ឬ សំណុំរឿង ០០២/០២[35]។ នៅក្នុងឧបសម្ព័ន្ធនៃសេចក្តីសម្រេចលើការបំបែកកិច្ចដំណើរការនីតិវិធីបន្ថែម អង្គជំនុំជម្រះសាលាដំបូងបានកត់សម្គាល់ថា ប្រសិនបើមានសំណើដោយមានសំអាងហេតុនោះ អង្គជំនុំជម្រះអាចពង្រីកវិសាលភាពនៃសំណុំរឿង ០០២/០២ ដើម្បីបញ្ចូលអង្គហេតុបន្ថែមលើអង្គហេតុដែលបានដាក់បញ្ចូលរួចហើយ ទាក់ទងនឹងការបោសសម្អាតនៅភូមិភាគឧត្តរ និងនៅភូមិភាគ បូព៌ា។ ប៉ុន្តែមិនមានសំណើបែបនេះទេ[36]។

១៣. នៅថ្ងៃទី ២៩ ខែ កក្កដា ឆ្នាំ ២០១៤ អង្គជំនុំជម្រះតុលាការកំពូលបានប្រកាសពីការផ្អាកបណ្តោះអាសន្ន នូវអង្គហេតុដែលស្ថិតក្រៅវិសាលនៃសំណុំរឿង ០០២/០១ និង ០០២/០២ ដោយរង់ចាំការសម្រេចសមស្របពីអង្គជំនុំជម្រះសាលាដំបូង[37]។ នៅខែ មករា ឆ្នាំ ២០១៥ ការអនុម័តលើវិធាន ៨៩ *ស្ទួនបី* នៃវិធានផ្ទៃក្នុង បានចែងយ៉ាងច្បាស់ថា អង្គជំនុំជម្រះមានសិទ្ធិអំណាចកាត់បន្ថយវិសាលភាពនៃការជំនុំជម្រះ ដោយដកចេញនូវអង្គហេតុមួយចំនួន ដែលមានចែងនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ។ បន្ទាប់ពីមានសំណើសុំបញ្ចប់កិច្ចដំណើរការនីតិវិធី អង្គជំនុំជម្រះសាលាដំបូងបានផ្តល់ឱកាសដល់ភាគីនានាឲ្យលើកឡើងពីការដកចេញតាមការស្នើសុំ ចំពោះអង្គហេតុដែលកំពុងពិចារណា។

១៤. ជាបញ្ហាបឋម អង្គជំនុំជម្រះសាលាដំបូង ដោះស្រាយចំពោះការជំទាស់របស់មេធាវីការពារក្តី ខៀវ សំផន។ មេធាវីការពារក្តី ខៀវ សំផន ហាក់ដូចជាជំទាស់ពីនីត្យានុកូលភាព នៃវិធាន៨៩*ស្ទួនបី* (៣) នៃវិធានផ្ទៃក្នុង ដែលអនុញ្ញាតឲ្យមានការពឹងផ្អែកលើភ័ស្តុតាងទាក់ទងនឹងអង្គហេតុដែលត្រូវបានដកចេញ នៅក្នុងកម្រិតដែលភ័ស្តុតាងទាំងនោះពាក់ព័ន្ធទៅនឹងអង្គហេតុដែលនៅសេសសល់ក្នុងវិសាលភាពនៃសំណុំរឿង។ អង្គជំនុំជម្រះសាលាដំបូងបានកត់សម្គាល់ថា មេធាវីការពារក្តី ខៀវ សំផន ប្រកាសដោយមិនមានភាពស៊ីសង្វាក់គ្នាមួយចំនួនថា អង្គជំនុំជម្រះសាលាដំបូងពុំមានជម្រើសផ្សេងឡើយ ក្រៅតែពី "បញ្ចប់កិច្ចដំណើរការនីតិវិធីសម្រាប់អង្គហេតុនានាដែលនៅ

---

[35] អង្គជំនុំជម្រះសាលាដំបូងកត់សម្គាល់ថា ការបញ្ជាក់ដោយសហមេធាវីនាំមុខ ដែលថាការយោងទៅរកមន្ទីរសន្តិសុខក្រូចឆ្មារ ត្រូវបានលប់ចោលដោយអចេតនានៅក្នុងសំណើសុំការបញ្ជាក់បំភ្លឺ៖ ចម្លើយតបរបស់សហមេធាវីនាំមុខ, កថាខណ្ឌ ២ ដល់៣។ សូមមើលផងដែរ សេចក្តីសម្រេចលើការបំបែកកិច្ចដំណើរការនីតិវិធីបន្ថែម, កថាខណ្ឌ ៤៥។

[36] ឧបសម្ព័ន្ធ៖ បញ្ជីនៃកថាខណ្ឌ និងផ្នែកនៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ ទាក់ទងសំណុំរឿង០០២/០២, ឯកសារ E301/9/1.1 ចុះថ្ងៃទី ០៤ ខែ មេសា ឆ្នាំ ២០១៤, ជើងទំព័រ ៩។

[37] សេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូល, កថាខណ្ឌ ៨៨ ដល់៩០។

សេសសល់" ដើម្បីបំពេញនូវតម្រូវការសម្រាប់សច្ចភាពផ្លូវច្បាប់ និងដើម្បីធានានូវការជំនុំជម្រះឱ្យបានឆាប់រហ័ស ប៉ុន្តែម្យ៉ាងទៀត ជំទាស់ការអនុវត្តវិធាន ៨៩ *ស្ទួនបី* ដែលគោលបំណងរបស់វិធាននេះគឺប្រាកដណាស់ដើម្បី "ធានានូវកិច្ចដំណើរការនីតិវិធីប្រកបដោយយុត្តិធម៌ មានអត្ថន័យ និងឆាប់រហ័ស"។

១៥. ការដែលមិនមានបទប្បញ្ញត្តិណាមួយនៅក្នុងច្បាប់ជាតិកម្ពុជា ដែលប្រមើលឃើញពីលទ្ធភាពនៃការកាត់បន្ថយវិសាលភាពនៃការជំនុំជម្រះគឺមិនមែនជាទឡ្ហីករណ៍មានសុពលភាពទាក់ទងទៅនឹងនីត្យានុកូលភាពនៃវិធាន ៨៩ *ស្ទួនបី* នៃវិធានផ្ទៃក្នុងឡើយ។ អង្គជំនុំជម្រះសាលាដំបូងបានបដិសេធនាពេលកន្លងមកនូវសំណើសុំមោឃភាពវិធានផ្ទៃក្នុង ដោយសម្រេចស្របតាមសំអាងហេតុរបស់អង្គបុរេជំនុំជម្រះ៖

> វិធានផ្ទៃក្នុង [...] បង្កើតជាប្រព័ន្ធច្បាប់នីតិវិធីមួយដោយខ្លួនឯង ដែលពាក់ព័ន្ធនឹងកាលៈទេសៈពិសេសរបស់ អ.វ.ត.ក ហើយត្រូវបានអនុម័ត និងមានការយល់ស្របពីកិច្ចប្រជុំពេញអង្គនៃ អ.វ.ត.ក។ វិធានផ្ទៃក្នុងនេះមិនផ្ទុយនឹងក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាឡើយ ប៉ុន្តែគោលបំណងរបស់ អ.វ.ត.ក ខុសគ្នាជាសំខាន់ពីដំណើរការសាមញ្ញរបស់តុលាការព្រហ្មទណ្ឌកម្ពុជា ដែលតម្រូវឱ្យ អ.វ.ត.ក មានប្រព័ន្ធមួយដែលមានលក្ខណៈពិសេស។ ដូច្នេះវិធានផ្ទៃក្នុងជាលិខិតូបករណ៍ចម្បងដែលយើងគួរនឹងយកមកពិនិត្យមើលក្នុងការកំណត់នីតិវិធីនៅចំពោះមុខ អ.វ.ត.ក ក្នុងករណីមានភាពខុសគ្នារវាងនីតិវិធីនៃវិធានផ្ទៃក្នុង និងក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា"[38]

១៦. ស្រដៀងគ្នានេះដែរ ដោយសារតែវិធាន ៨៩ *ស្ទួនបី* នៃវិធានផ្ទៃក្នុង ត្រូវបានអនុម័តស្របតាមក្របខណ្ឌគតិយុត្តិរបស់ អ.វ.ត.ក បទប្បញ្ញត្តិទាំងអស់របស់វិធាននេះមានសុពលភាព និងនៅជាធរមានក្នុងករណីនេះ។ ការនេះរួមបញ្ចូលទាំងបទប្បញ្ញត្តិនៅក្នុង វិធាន ៨៩ *ស្ទួនបី* (៣) នៃវិធាន

---

[38] សេចក្តីសម្រេចលើអញ្ញត្រកម្មរបស់ នួន ជា ពាក់ព័ន្ធនឹងការចោទប្រកាន់ពីចរិតលក្ខណៈផ្ទុយគ្នា នៃវិធានផ្ទៃក្នុងរបស់ អ.វ.ត.ក ទៅនឹងច្បាប់រដ្ឋធម្មនុញ្ញ, ឯកសារ E51/14 ចុះថ្ងៃទី ០៨ ខែ សីហា ឆ្នាំ ២០១១, កថាខណ្ឌ ៧ យោងទៅរកសេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍របស់ នួន ជា ប្រឆាំងនឹងដីកាសម្រេចបដិសេធសំណើសុំមោឃភាព, ឯកសារ D55/I/8 ចុះថ្ងៃទី ២៦ ខែ សីហា ឆ្នាំ២០០៨, កថាខណ្ឌ ១៤។

ផ្ទៃក្នុង ដែលអនុញ្ញាតឱ្យភស្តុតាង "ដែលពាក់ព័ន្ធនឹងអង្គហេតុដែលត្រូវបានដកចេញ" អាច "ត្រូវបានប្រើប្រាស់ក្នុងករណីដែលភស្តុតាងនោះពាក់ព័ន្ធនឹងអង្គហេតុដែលនៅសេសសល់ផ្សេងទៀត"។[39]

១៧. ឥឡូវនេះ អង្គជំនុំជម្រះនឹងពិចារណាថាតើ លក្ខខណ្ឌតម្រូវសម្រាប់ការកាត់បន្ថយវិសាលភាពនៃសំណុំរឿង ០០២ អនុលោមតាមវិធាន ៨៩ *ស្ទួនបី* នៃវិធានផ្ទៃក្នុង ត្រូវបានបំពេញដែរ ឬ យ៉ាងណា។ អង្គជំនុំជម្រះតុលាការកំពូលបានផ្តល់នូវគោលការណ៍ណែនាំច្បាស់លាស់ អំពីការវាយតម្លៃទៅលើលក្ខណៈវិនិច្ឆ័យនៃ "ភាពជាតំណាង" ដោយបានពិចារណាទៅលើការអនុវត្តរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិទាក់ទងការដកចេញអង្គហេតុនិងការកាត់បន្ថយវិសាលភាពនៃការជំនុំជម្រះ[40]។ ទោះបីជាគោលការណ៍ណែនាំនេះត្រូវបានកំណត់ឡើងនៅក្នុងបរិបទនៃការបំបែកកិច្ចដំណើរការនីតិវិធីក៏ដោយ ក៏អង្គជំនុំជម្រះសាលាដំបូងពិចារណាថា គោលការណ៍ណែនាំនេះអាចអនុវត្តបានដូចគ្នាក្នុងការវាយតម្លៃលើភាពជាតំណាងសម្រាប់គោលបំណងនៃវិធាន៨៩*ស្ទួនបី*នៃវិធានផ្ទៃក្នុង។ អង្គជំនុំជម្រះតុលាការកំពូល តម្រូវឱ្យមានការថ្លឹងថ្លែងរវាង "ប្រយោជន៍នៃការជំនុំជម្រះឱ្យបានឆាប់រហ័ស និងប្រកបដោយយុត្តិធម៌" និងតម្រូវការឱ្យមានសវនាការដែលជា "តំណាងសមស្រប" នៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ"។ អង្គជំនុំជម្រះបានសន្និដ្ឋានថា "គោលបំណងដ៏សំខាន់បំផុតនៃលក្ខខណ្ឌនៃភាពជាតំណាង គឺដើម្បីជ្រើសរើសអង្គហេតុក្នុងចំនួនអប្បបរមាដែលនឹងឆ្លុះបញ្ចាំងដ៏សមហេតុផលនូវវិសាលភាព និងចរិតលក្ខណៈទាំងមូលនៃអំពើឧក្រិដ្ឋ និងការទទួលខុសត្រូវជាលក្ខណៈបុគ្គលដែលត្រូវបានចោទប្រកាន់"[41]។

១៨. ដោយបានពិចារណាទៅលើសារណារបស់ភាគី ព្រមជាមួយលក្ខណៈនៃអង្គហេតុដែលកំពុងពិចារណា អង្គជំនុំជម្រះសាលាដំបូងសម្រេចថា អង្គហេតុដែលបានជំនុំជម្រះ ឬ ដែលត្រូវជំនុំជម្រះនៅក្នុងសំណុំរឿង ០០២/០១ និងសំណុំរឿង ០០២/០២ គឺជាតំណាងនៃវិសាលភាពរបស់ដីកា

---

[39] អង្គជំនុំជម្រះកត់សម្គាល់ឃើញថានៅក្នុងវិធាន ៨៩ ស្ទួន៣ នៃវិធានផ្ទៃក្នុងជាភាសាអង់គ្លេសគឺប្រើប្រាស់ពាក្យ "remaining facts" ហើយនៅក្នុងវិធានផ្ទៃក្នុងជាភាសាបារាំងប្រើប្រាស់ពាក្យ "des faits restant l'objet du procès" ដែលបញ្ជាក់ថាវិធាននេះគឺពាក់ព័ន្ធនឹងអង្គហេតុនៅនៅសេសសល់នៅក្នុងវិសាលភាពនៃសំណុំរឿង។

[40] សេចក្តីសម្រេចរបស់ អ.ជ.ត.ក លើសេចក្តីសម្រេចលើកទីពីររបស់ អ.ជ.ស.ដ ស្តីពីការបំបែកកិច្ចដំណើរការនីតិវិធី, កថាខណ្ឌ ៦១ ដល់ ៧០។

[41] សេចក្តីសម្រេចរបស់ អ.ជ.ត.ក លើសេចក្តីសម្រេចលើកទីពីររបស់ អ.ជ.ស.ដ ស្តីពីការបំបែកកិច្ចដំណើរការនីតិវិធី, កថាខណ្ឌ ៦៤។ សូមមើលផងដែរ សេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូល, កថាខណ្ឌ ៨៧។

បញ្ជូនរឿងទៅជំនុំជម្រះដូចមានចែងក្នុងដីកាដំណោះស្រាយ។ អង្គហេតុដែលត្រូវបានស្តាប់ការពិភាក្សាដេញដោលនៅក្នុងសំណុំរឿង ០០២/០១ និង ០០២/០២ រួមបញ្ចូលនូវបទចោទប្រកាន់តាមផ្លូវច្បាប់ទាំងអស់សម្រាប់ឧក្រិដ្ឋកម្មដែលត្រូវបានបញ្ជូនទៅជំនុំជម្រះ និងគ្របដណ្តប់លើហេតុការណ៍សំខាន់បំផុតនៅក្នុងអំឡុងពេលដែលឧក្រិដ្ឋកម្មត្រូវបានចោទប្រកាន់បានកើតឡើង។ អង្គហេតុដែលបានស្តាប់ការពិភាក្សាដេញដោល ក៏បានគ្របដណ្តប់ផងដែរទៅលើឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់ ដែលបានប្រព្រឹត្តិឡើងនៅក្នុងទីតាំងភូមិសាស្ត្រផ្សេងៗគ្នានៅទូទាំងប្រទេសកម្ពុជាក្នុងអំឡុងយុត្តាធិការពេលវេលារបស់ អ.វ.ត.ក ហើយបានឆ្លុះបញ្ចាំងដ៏សមស្របនូវអំពើឧក្រិដ្ឋ និងការទទួលខុសត្រូវជាលក្ខណៈបុគ្គលរបស់ជនជាប់ចោទដែលត្រូវបានចោទប្រកាន់ទាំងមូល។

១៩. សម្រាប់គោលបំណងនៃវិធាន៨៩ *ស្ទួន* នៃវិធានផ្ទៃក្នុង អង្គជំនុំជម្រះក៏ចាំបាច់ត្រូវធានាផងដែរអំពីដំណើរការនីតិវិធីប្រកបដោយយុត្តិធម៌ មានអត្ថន័យ និងឆាប់រហ័ស នៅពេលពិចារណាទៅលើលក្ខខណ្ឌតម្រូវចាំបាច់សម្រាប់កិច្ចដំណើរការនីតិវិធីនៅចំពោះមុខ អ.វ.ត.ក។

២០. នៅពេលវាយតម្លៃថា តើដំណើរការនីតិវិធីសវនាការមានភាពយុត្តិធម៌ និងមានអត្ថន័យដែរ ឬ អត់នោះ កត្តាមួយក្នុងចំណោមកត្តាផ្សេងៗដែលអង្គជំនុំជម្រះបានពិចារណា គឺគោលជំហររបស់ដើមបណ្តឹងរដ្ឋប្បវេណី។ ដោយសារដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿង ០០២ ចូលរួមជាក្រុមនោះ អង្គជំនុំជម្រះបានពិចារណាថា តើដំណើរការយុត្តិធម៌មានអត្ថន័យដែរ ឬ អត់ សម្រាប់ក្រុមទាំងមូល។ អង្គជំនុំជម្រះសាលាដំបូងទទួលស្គាល់ថា ជនរងគ្រោះដោយផ្ទាល់ ឬ ដោយប្រយោលដែលបានទទួលរងផលប៉ះពាល់ត្រូវបានទទួលយកជាដើមបណ្តឹងរដ្ឋប្បវេណី ដោយសារការចោទប្រកាន់ដែលស្ថិតក្រៅវិសាលភាពនៃសំណុំរឿង ០០២/០១ និង ០០២/០២ នោះ ទទួលបានផលប្រយោជន៍ពីការពិភាក្សាដេញដោលអង្គហេតុទាំងអស់នេះ។ អង្គជំនុំជម្រះកត់សម្គាល់ថា មានដើមបណ្តឹងរដ្ឋប្បវេណីចំនួន ៤៤៦ នាក់ បានទទួលរងផលប៉ះពាល់។ ប្រាកដណាស់ថានេះជាក្រុមដើមបណ្តឹងរដ្ឋប្បវេណីភាគតិចទេ បើធៀបទៅនឹងក្រុមរួមទាំងមូលដែលមានដើមបណ្តឹងរដ្ឋប្បវេណីជាង ៣៨០០ នាក់។ បន្ថែមលើនេះ ដូចដែលសហមេធាវីនាំមុខបានកត់សម្គាល់ថា ដើមបណ្តឹងរដ្ឋប្បវេណីដែលទទួលរងផលប៉ះពាល់ជាច្រើន ក៏ជាជនរងគ្រោះជាក់ស្តែងនៃអង្គហេតុនានាដែលគ្របដណ្តប់នៅក្នុងសំណុំរឿង ០០២/០១ និង០០២/០២ ដែរ[42]។ ហេតុដូច្នេះ អង្គជំនុំជម្រះជឿជាក់ថា

[42] ក្នុងអំឡុងពេលធ្វើសារណាផ្ទាល់មាត់ សហមេធាវីនាំមុខបានកត់សម្គាល់បន្ថែមថា មានតែដើមបណ្តឹងរដ្ឋប្បវេណីដែលរងផលប៉ះពាល់៣៤នាក់ប៉ុណ្ណោះ ដែលត្រូវបានទទួលស្គាល់ដោយផ្អែកលើមូលដ្ឋាននៃអង្គហេតុ ដែលមិនត្រូវជំនុំជម្រះនៅក្នុងសំណុំរឿង

ការកាត់បន្ថយវិសាលភាពសំណុំរឿង០០២ គឺមានលក្ខណៈសត្យានុម័តសម្រាប់ជាប្រយោជន៍ដល់ដំណើរការនីតិវិធីប្រកបដោយយុត្តិធម៌ មានអត្ថន័យ និងឆាប់រហ័ស សម្រាប់បណ្តឹងដើមបណ្តឹងរដ្ឋប្បវេណី។ អង្គជំនុំជម្រះសាលាដំបូងកត់សម្គាល់ផងដែរថា យោងតាមវិធាន៨៩ *ស្ទួនបី* (៤)នៃវិធានផ្ទៃក្នុង សេចក្តីសម្រេចនេះមិនប៉ះពាល់ដល់ការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណី ឬសមាសភាពនៃបណ្តុំដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿងនេះឡើយ។

២១. អង្គជំនុំជម្រះសាលាដំបូងកត់សម្គាល់ពីតម្រូវការស្របច្បាប់របស់ដើមបណ្តឹងរដ្ឋប្បវេណីជាបុគ្គលចំពោះវិធានការក្រៅផ្លូវតុលាការដែលគាំទ្រដល់ជីវភាពរស់នៅប្រចាំថ្ងៃរបស់ពួកគាត់ ហើយនឹងអនុញ្ញាតឱ្យពួកគាត់អាចនិយាយចេញនូវអ្វីដែលពួកគាត់បានជួបប្រទះ ជាពិសេសទាក់ទងទៅនឹងអង្គហេតុដែលកំពុងពិចារណា។ ទោះជាយ៉ាងនេះក្តី អង្គជំនុំជម្រះសាលាដំបូង បានកត់សម្គាល់ថាការកាត់បន្ថយវិសាលភាពនៃសំណុំរឿង ០០២ មិនបានរារាំងសហមេធាវីនាំមុខឡើយក្នុងការស្នើសុំឱ្យមានការទទួលស្គាល់នូវគម្រោងជាក់លាក់ដែលបានស្នើសុំអនុលោមតាមវិធាន ២៣ *ស្ទួនបួន* (២)(ខ) នៃវិធានផ្ទៃក្នុង ធ្វើឱ្យការស្នើសុំសំណងដើម្បីជាប្រយោជន៍សម្រាប់ដើមបណ្តឹងរដ្ឋប្បវេណីទាំងមូលនោះមានប្រសិទ្ធភាពយ៉ាងត្រឹមត្រូវ រួមទាំងសម្រាប់ដើមបណ្តឹងរដ្ឋប្បវេណីដែលរងផលប៉ះពាល់ផងដែរ។

២២. អង្គជំនុំជម្រះក៏បានពិចារណាផងដែរអំពីរយៈពេលនៃកិច្ចដំណើរការនីតិវិធីរហូតមកដល់បច្ចុប្បន្ននៅក្នុងសំណុំរឿង ០០២, វ័យរបស់ជនជាប់ចោទ, អាយុ និងលទ្ធភាពចូលរួមរបស់សាក្សី[43] ការពន្យារពេលដែលមិនអាចជៀសវាងបាន និងចិរវេលាដែលចាំបាច់ត្រូវបញ្ចប់ការជំនុំជម្រះទីបី ព្រមទាំងគោលជំហររបស់ភាគីចំពោះតម្រូវការក្នុងការជំនុំជម្រះបន្ថែមទៀតនៅក្នុងសំណុំរឿងនេះ។ អង្គជំនុំជម្រះយល់ឃើញថា ការបន្តការជំនុំជម្រះចំពោះអង្គហេតុដែលកំពុងពិចារណានេះ នឹងមិនមែនជាប្រយោជន៍នៃនីតិវិធីប្រកបដោយយុត្តិធម៌ និងឆាប់រហ័សនោះឡើយ។ ហេតុដូច្នេះ ដើម្បីជា

---

០០២។ ទោះជាយ៉ាងនេះក្តីសហមេធាវីនាំមុខបានកត់សម្គាល់ថា ចំនួននេះមិនរួមបញ្ចូលដើមបណ្តឹងរដ្ឋប្បវេណី ដែលត្រូវបានទទួលស្គាល់ទាក់ទងការប្រព្រឹត្តិទៅលើពុទ្ធសាសនិកជន និងការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទីបីឡើយ, ប្រតិចារឹកសវនាការ ចុះថ្ងៃទី ១១ ខែ មករា ឆ្នាំ ២០១៧, ទំព័រ ៥ ដល់៦ (សេចក្តីព្រាង))។

[43] អង្គជំនុំជម្រះបានកត់សម្គាល់ថា សូម្បីនៅក្នុងសំណុំរឿង ០០២/០២ ក៏អង្គជំនុំជម្រះជួបការលំបាកដោយសារតែមានការកើនឡើងនូវចំនួនសាក្សី និងដើមបណ្តឹងរដ្ឋប្បវេណី ដែលមិនអាចមកផ្តល់សក្ខីកម្មបានដោយសារមរណភាព ឬ ស្ថានភាពសុខភាពធ្ងន់ធ្ងរខ្លាំង។

ប្រយោជន៍នៃដំណើរការតុលាការប្រកបដោយយុត្តិធម៌ មានអត្ថន័យ និងឆាប់រហ័សនោះ អង្គជំនុំ-ជម្រះសម្រេចដកចេញ និងបញ្ចប់កិច្ចដំណើរការនីតិវិធីពាក់ព័ន្ធនឹងអង្គហេតុដែលនៅសេសសល់។

**តាមសំអាងហេតុដូចបានរៀបរាប់ខាងលើ អង្គជំនុំជម្រះសាលាដំបូង÷**

**បដិសេធ** ការជំទាស់របស់មេធាវីការពារក្តី ខៀវ សំផន ចំពោះវិធាន៨៩ *ស្ទួនបី* នៃវិធានផ្ទៃក្នុង។

**សម្រេច** កាត់បន្ថយវិសាលភាពនៃសំណុំរឿង ០០២ ដោយដកចេញនូវអង្គហេតុទាំងឡាយណាដែលមាននៅក្នុងដីកាដំណោះស្រាយសំណុំរឿង ០០២ ហើយដែលមិនត្រូវបានបញ្ចូលនៅក្នុងសំណុំរឿង ០០២/០១ ឬ សំណុំរឿង ០០២/០២ អនុលោមតាមវិធាន៨៩ *ស្ទួនបី*(១) នៃវិធានផ្ទៃក្នុង។ និង

**បញ្ចប់** កិច្ចដំណើរការនីតិវិធីពាក់ព័ន្ធនឹងអង្គហេតុទាំងឡាយណាដែលមាននៅក្នុងដីកាដំណោះស្រាយសំណុំរឿង ០០២ ហើយដែលមិនត្រូវបានបញ្ចូលនៅក្នុងសំណុំរឿង ០០២/០១ ឬ សំណុំរឿង ០០២/០២ អនុលោមតាម វិធាន ៨៩ *ស្ទួនបី*(៣) នៃវិធានផ្ទៃក្នុង។

ភ្នំពេញ ថ្ងៃទី ២៧ ខែ កុម្ភៈ ឆ្នាំ ២០១៧

**ប្រធានអង្គជំនុំជម្រះសាលាដំបូង**

TRIAL CHAMBER * E.C.C.C * C.E.T.C * CHAMBRE DE PREMIÈRE INSTANCE

**និល ណុន**